# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...៩៩១.....សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ ២០១៧

# ប្រកាសរួម
## ស្តីពី
## ការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៤៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ



ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- តាមការចាំបាច់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១** :

អនុញ្ញាតឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

កម្រងសេវាសាធារណៈនេះ មានបញ្ជាក់លម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងប្រកាសរួមនេះ។

**ប្រការ ២** :

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវា ក្នុងនោះរួមមាន ៖ តារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវា ពាក់ព័ន្ធនឹងការប្រមូលចំណូលខាងលើនេះ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយមូលហេតុជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវជាដើម។

**ប្រការ ៣** :

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និងបង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងធ្វើសលាកប័ត្រចំណូល។

**ប្រការ ៤ :**

ការបែងចែកភារកិច្ចលើការគ្រប់គ្រង ការប្រមូលចំណូល ពីការផ្តល់សេវាសាធារណៈ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវផ្ញើសេចក្តីប្រកាសនេះចំនួនមួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្តចំណូល។

**ប្រការ ៥ :**

រាល់ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបានបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៦ :**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលាតាមការកំណត់។

**ប្រការ ៧ :**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ ៨ :**

កម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបាន តាមការចាំបាច់តាមរយៈប្រកាសរួម។

**ប្រការ ៩ :**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០ :**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**សុខ ចិន្តា សោភា**

ចម្លងជូនៈ

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា

«ដើម្បីជូនជ្រាប»

- ដូចប្រការ ១០ «ដើម្បីមុខការ»
- ឯកសារ - កាលប្បវត្តិ

# តារាងឧបសម្ព័ន្ធ

## ភ្ជាប់នឹងប្រកាសរួមលេខ ៩៩១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

## ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| **តម្លៃសេវានៃគណៈកម្មាធិការវិនិយោគកម្ពុជា** | | | | |
| 1 | ការផ្តល់សេវាពិគ្រោះយោបល់ | អត់គិតថ្លៃ | | |
| 2 | រៀបចំកម្មវិធីទស្សនកិច្ចស្វែងយល់របស់គណៈប្រតិភូវិនិយោគ | អត់គិតថ្លៃ | | |
| 3 | ផ្តល់ឯកសារពាក់ព័ន្ធនឹងការវិនិយោគ | អត់គិតថ្លៃ | | |
| 4 | ផ្តល់សេវាមគ្គុទេសក៍ | អត់គិតថ្លៃ | | |
| 5 | សេវារៀបចំឱ្យមានការជួបគ្នារវាងអ្នកវិនិយោគក្នុងស្រុក និងបរទេស | អត់គិតថ្លៃ | | |
| 6 | ការសម្របសម្រួលសុំទិដ្ឋាការ | អត់គិតថ្លៃ | | |
| 7 | ការសម្របសម្រួលចុះបញ្ជី | អត់គិតថ្លៃ | | |
| 8 | សុំលុបឈ្មោះក្រុមហ៊ុន | អត់គិតថ្លៃ | 15ថ្ងៃ | |
| 9 | សុំបញ្ជាក់ដើមទុនវិនិយោគ | អត់គិតថ្លៃ | 5ថ្ងៃ | |
| 10 | កែតម្លៃយថាប្រភេទទំនិញ | អត់គិតថ្លៃ | 15ថ្ងៃ | |
| 11 | បិទក្រុមហ៊ុន | អត់គិតថ្លៃ | 10ថ្ងៃ | |
| 12 | ផ្អាកសកម្មភាពផលិតកម្ម | អត់គិតថ្លៃ | 10ថ្ងៃ | |
| 13 | បំពេញបែបបទសុំដកប្រាក់ | អត់គិតថ្លៃ | 28ថ្ងៃ | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 14 | ពន្យាសុពលភាពលិខិតនាំចូល | អត់គិតថ្លៃ | 3ថ្ងៃ | 6ខែ |
| 15 | វិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ C.O.C | អត់គិតថ្លៃ | 10ថ្ងៃ | |
| 16 | ប្ដូរយថាប្រភេទទំនិញ | អត់គិតថ្លៃ | 15ថ្ងៃ | |
| 17 | សំណើសុំបន្ថែមលើបញ្ជីនាំចូលចាស់ | អត់គិតថ្លៃ | 10ថ្ងៃ | |
| 18 | ប្ដូរមុខសញ្ញាផលិតកម្ម | អត់គិតថ្លៃ | 15ថ្ងៃ | |
| 19 | នាំចូលផ្ទាំងក្រណាត់ចាក់តាមរូបភាព OPA | 2,000,000 | 3ថ្ងៃ | |
| 20 | ប្ដូរទីស្នាក់ការក្រុមហ៊ុន | អត់គិតថ្លៃ | 10ថ្ងៃ | |
| 21 | សុំកម្ទេចគ្រឿងម៉ាស៊ីនចាស់ៗ | អត់គិតថ្លៃ | 15ថ្ងៃ | |
| 22 | ផ្ទេរគ្រឿងម៉ាស៊ីន | 2,000,000 | 15ថ្ងៃ | |
| 23 | នាំចេញគ្រឿងម៉ាស៊ីន | 2,000,000 | 15ថ្ងៃ | |
| 24 | លក់គ្រឿងម៉ាស៊ីនចាស់ៗ | 2,000,000 | 15ថ្ងៃ | |
| 25 | សំណើសុំនាំចូលដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋ | 4,000,000 | 15ថ្ងៃ | 12ខែ |
| 26 | ពង្រីកផលិតកម្ម | 2,000,000 | 15ថ្ងៃ | |
| 27 | បន្ថែមមុខសញ្ញាផលិតកម្ម | អត់គិតថ្លៃ | 15ថ្ងៃ | |
| 28 | ផ្ទេរភាគហ៊ុន | 2,000,000 | 10ថ្ងៃ | |
| 29 | ប្ដូរទីតាំងរោងចក្រ | 2,000,000 | 10ថ្ងៃ | |
| 30 | ប្ដូរនាមករណ៍ក្រុមហ៊ុន | 2,000,000 | 10ថ្ងៃ | |
| 31 | ប្ដូរអភិបាល ឬប្ដូរអ្នកតំណាង | 2,000,000 | 10ថ្ងៃ | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 32 | បន្ថយ-បន្ថែមដើមទុនចុះបញ្ជី | 2,000,000 | 10ថ្ងៃ | |
| 33 | ការទិញ និងរំលាយបញ្ចូលគ្នា | 4,000,000 | 10ថ្ងៃ | |
| 34 | ការពិនិត្យ និងអនុម័តផែនការមេនៃបណ្តាកោះ និងឆ្នេរ | 40,000,000 | 30ថ្ងៃ | |
| 35 | គម្រោងវិនិយោគថ្មី | | | |
| | - ឧស្សាហកម្ម | 15,000,000 | 28ថ្ងៃ | |
| | - ទេសចរណ៍ | 15,000,000 | 28ថ្ងៃ | |
| | - ហេដ្ឋារចនាសម្ព័ន្ធ | 15,000,000 | 28ថ្ងៃ | |
| | - កសិកម្ម | 15,000,000 | 28ថ្ងៃ | |
| | - រ៉ែ និងធនធានធម្មជាតិ | 15,000,000 | 28ថ្ងៃ | |
| 36 | ការងារចុះពិនិត្យគម្រោងវិនិយោគថ្មី(ទោះជាប៉ុន្មានលើកក៏ដោយ) | | | |
| | - តិចជាង 100 គម | 6,000,000 | | |
| | - ពី 101-200 គម | 8,000,000 | | |
| | - ពី 201 គមឡើង | 10,000,000 | | |
| **គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា** | | | | |
| 1 | ការផ្តល់សេវាពិគ្រោះយោបល់ | អត់គិតថ្លៃ | | |
| 2 | រៀបចំកម្មវិធីទស្សនកិច្ចស្វែងយល់របស់គណៈប្រតិភូវិនិយោគ | អត់គិតថ្លៃ | | |
| 3 | ផ្តល់ឯកសារពាក់ព័ន្ធនិងការវិនិយោគ | អត់គិតថ្លៃ | | |
| 4 | ផ្តល់សេវាមគ្គុទេសក៍ | អត់គិតថ្លៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 5 | សេវារៀបចំឱ្យមានការជួបគ្នារវាងអ្នកវិនិយោគក្នុងស្រុក និងបរទេស | អត់គិតថ្លៃ | | |
| 6 | ការសម្របសម្រួលសុំទិដ្ឋាការ | អត់គិតថ្លៃ | | |
| 7 | ការសម្របសម្រួលចុះបញ្ជី | អត់គិតថ្លៃ | | |
| 8 | សុំលុបឈ្មោះក្រុមហ៊ុន | អត់គិតថ្លៃ | 3ថ្ងៃ | |
| 9 | សុំបញ្ជាក់ដើមទុនវិនិយោគ | អត់គិតថ្លៃ | 3ថ្ងៃ | |
| 10 | កែតម្លៃយថាប្រភេទទំនិញ | អត់គិតថ្លៃ | 3ថ្ងៃ | |
| 11 | បិទក្រុមហ៊ុន | អត់គិតថ្លៃ | 3ថ្ងៃ | |
| 12 | ផ្អាកសកម្មភាពផលិតកម្ម | អត់គិតថ្លៃ | 3ថ្ងៃ | |
| 13 | បំពេញបែបបទសុំដកប្រាក់កក់ | អត់គិតថ្លៃ | 3ថ្ងៃ | |
| 14 | ពន្យាសុពលភាពលិខិតនាំចូល | អត់គិតថ្លៃ | 3ថ្ងៃ | 6ខែ |
| 15 | វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ C.O.C | អត់គិតថ្លៃ | 3ថ្ងៃ | |
| 16 | ប្តូរយថាប្រភេទទំនិញ | អត់គិតថ្លៃ | 3ថ្ងៃ | |
| 17 | សំណើសុំបន្ថែមលើបញ្ជីនាំចូលចាស់ | អត់គិតថ្លៃ | 3ថ្ងៃ | |
| 18 | ប្តូរមុខសញ្ញាផលិតកម្ម | អត់គិតថ្លៃ | 3ថ្ងៃ | |
| 19 | នាំចូលផ្ទាំងក្រណាត់ចាក់តាមរូបភាព OPA | 2,000,000 | 3ថ្ងៃ | |
| 20 | ប្តូរទីស្នាក់ការក្រុមហ៊ុន | អត់គិតថ្លៃ | 5ថ្ងៃ | |
| 21 | សុំកម្ទេចគ្រឿងម៉ាស៊ីនចាស់ៗ | អត់គិតថ្លៃ | 5ថ្ងៃ | |
| 22 | ផ្ទេរគ្រឿងម៉ាស៊ីន | 2,000,000 | 5ថ្ងៃ | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 23 | នាំចេញគ្រឿងម៉ាស៊ីន | 2,000,000 | 5ថ្ងៃ | |
| 24 | លក់គ្រឿងម៉ាស៊ីនចាស់ៗ | 2,000,000 | 3ថ្ងៃ | |
| 25 | សំណើសុំនាំចូល - ដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋ | 1,600,000 | 3ថ្ងៃ | 12ខែ |
| 26 | ពង្រីកផលិតកម្ម | 2,000,000 | 5ថ្ងៃ | |
| 27 | បន្ថែមមុខសញ្ញាផលិតកម្ម | អត់គិតថ្លៃ | 5ថ្ងៃ | |
| 28 | ផ្ទេរភាគហ៊ុន | 2,000,000 | 5ថ្ងៃ | |
| 29 | ប្ដូរនាមករណ៍ក្រុមហ៊ុន | 2,000,000 | 5ថ្ងៃ | |
| 30 | ប្ដូរអភិបាល ឬប្ដូរអ្នកតំណាង | 2,000,000 | 5ថ្ងៃ | |
| 31 | បន្ថយ-បន្ថែមដើមទុនចុះបញ្ជី | 2,000,000 | 5ថ្ងៃ | |
| 32 | ការទិញ និងរំលាយបញ្ចូលគ្នា | 4,000,000 | 5ថ្ងៃ | |
| 33 | គម្រោងវិនិយោគថ្មី | 15,000,000 | 28ថ្ងៃ | |
| **គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា** | | | | |
| 1 | កាពិនិត្យ និងអនុម័តពាក្យសុំនាំចូលឧបករណ៍ សម្ភារៈមធ្យោបាយដោយ រដ្ឋទទួលបន្ទុកបង់ពន្ធជំនួសសម្រាប់ការអនុវត្តន៍គម្រោងវិនិយោគក្នុងក្រប ខ័ណ្ឌជំនួយទ្វេភាគី ពហុភាគី និង អង្គការក្រៅរដ្ឋាភិបាលទាំងអស់ | 200,000 | 10ថ្ងៃ | 2ខែ |